


# នរណាសត្រូវពិតរបស់ខ្មែរ?

ថ្ងៃ១៧មេសា១៩៧៥ ប្រទេសកម្ពុជាត្រូវបានកាន់កាប់ត្រួតត្រា ដោយក្រុមបនបរិវារប្រល័យពូជសាសន៍ខ្មែរក្រហមហាណូយ ដែលនៅក្រោមបញ្ជារការនៃ « អង្គការលើ » និង « អង្គការចាត់តាំង » ដែលជាក្បាលម៉ាស៊ីននៃមេបនប្រល័យពូជសាសន៍វៀតណាមក្រហមយួនហាណូយ ដែលបានសម្លាប់ខ្មែរអស់ជាង៣លាននាក់ មិនថា: ខ្មែរនោះមាននិន្នាការជាអ្វីក៏ដោយ ។ មានខ្មែរក្រហមបរិសុទ្ធមួយចំនួនធំ ក៏ត្រូវបានខ្មែរក្រហមហាណូយសម្លាប់ដោយឧបាយកលពិសពុលព្រៃផ្សៃយ៉ាងសម្ងាត់បំផុត ក្នុងការលាបមុខខ្មែរប្រើ « យុទ្ធសាស្ត្រខ្ចីដៃខ្មែរសម្លាប់ខ្មែរ » នៃមេបនប្រល័យពូជសាសន៍វៀតណាមក្រហមយួនហាណូយនោះឯង ។

ដូចជាករណីបានសម្លាប់មេខ្មែរក្រហមបរិសុទ្ធគឺលោកហ៊ូ-នឹម លោកហ៊ូ-យន់ លោកនួន-ឃឿន ជាដើមរួមទាំងខ្មែរក្រហមបរិសុទ្ធមួយចំនួនធំផ្សេងទៀត ។ លោកនួន-ឃឿន ដែលជាបញ្ញវ័ន្តខ្មែរមួយរូប មានដើមកំណើតនៅខេត្តសៀមរាប និងមានទីលំនៅមិនឆ្ងាយពីប្រាសាទអង្គរប៉ុន្មានគីឡូម៉ែត្រផងនោះ លោកបានបន្សល់ទុកនូវស្នាមស្នាដៃរបស់លោក ដែលបានចងក្រងរឿងរ៉ាវជាប្រវត្តិសាស្ត្រ ពីអតីតកាល បច្ចុប្បន្នកាល រហូត ត ទៅអនាគត ដើម្បីបកអាក្រាតឆ្លុះបញ្ចាំងអំពីមហិច្ឆិតាឈ្លានពានរបស់មេបនប្រល័យពូជសាសន៍យួនក្រហមហាណូយ វាតទីនិយម ក្រោមចំណងជើងថា: « ដំណើរឆ្ពោះទៅទិសខាងលិច » នៃប្រជាជនវៀតណាមយួនក្រហម ។ អត្ថបទនេះ លោកបានសរសេរដៅទុកសំរាប់កុលបុត្រ កុលធីតាខ្មែរគ្រប់ជំនាន់ ឲ្យប្រុងប្រយ័ត្ន ដោយប្រើសតិបញ្ញាស្មារតី ជាតិនិយមពិតប្រាកដ ។ អត្ថបទមួយនេះ លោកបានសរសេរចាប់តាំងពីថ្ងៃទី២៨ខែកញ្ញាឆ្នាំ១៩៦៩ នោះមកម្ល៉េះ ។

ដោយ « ការបិទទ្វារព្រំដែន » ទាំងខាងកើត និងខាងលិច តាមការបញ្ជាររបស់ « អង្គការលើ » និង « អង្គការចាត់តាំង » វៀតណាមយួនក្រហមហាណូយ បានបញ្ជារខ្មែរក្រហមបរិសុទ្ធ ដោយបានប្រែក្លាយពីការបញ្ជារថា: « បិទទ្វារព្រំដែន » ទៅជាការបញ្ជារបញ្ឆោតថា: « ការពារព្រំដែន » ទៅវិញ ។ ពីព្រោះខ្លាចពួកយួន-សៀម រំលោភឈ្លានពានកម្ពុជា! ចំពោះកងយុទ្ធមិត្រខ្មែរក្រហមបរិសុទ្ធ ដែលមានឆន្ទះមនសិកាស្នេហាជាតិពិតប្រាកដ កាលបើបានឮការបញ្ជារពី « ថ្នាក់លើ ឬអង្គការលើ » ថា: « ការពារព្រំដែនកម្ពុជា » កុំឲ្យយួន-សៀមរំលោភឈ្លានពានកម្ពុជានោះ ខ្មែរក្រហមបរិសុទ្ធក៏សូម

ទទួលស្វាគមន៍យ៉ាងពេញចិត្ត ដោយខំព្យាយាមត្រៀមលក្ខណៈប្រយុទ្ធយ៉ាងអង់អាចក្លាហានមុះមុត ជាមួយបច្ចាមិត្តវៀត ណាមយួនក្រហមហាណូយឈ្លានពានកម្ពុជា មិនខ្លាចស្លាប់សោះឡើយ ។

« អង្គការលើ » វៀតណាមយួនក្រហមហាណូយឈ្លានពានកម្ពុជា បានប្រើយុទ្ធសាស្ត្រវាយបញ្ឆោតតាម បណ្តោយព្រំដែនខ្មែរ-យួន ដើម្បីកន្ត្រាក់ស្មារតីកងយុទ្ធមិត្តខ្មែរក្រហមបរិសុទ្ធ ឱយចាប់អារម្មណ៍អំពីបញ្ហាព្រំដែន ព្យា យាម ការពារបូរណភាពទឹកដី កុំឲ្យចាប់អារម្មណ៍អ្វីអំពីបញ្ហាផ្ទៃក្នុងកម្ពុជា ស្តីពីសុខទុក្ខរបស់ពលរដ្ឋខ្មែរដែលហៅថា « សមរ ភូមិក្រោយ » ខិតខំបង្កបង្កើនផល សំរាប់ផ្គត់ផ្គង់ស្បៀងជូនយុទ្ធមិត្ត « សមរភូមិមុខ » វាយកំចាត់ខ្មាំងសត្រូវវៀតណាមយួន ក្រហមហាណូយឈ្លានពានកម្ពុជា ។

« អង្គការលើ » វៀតណាមយួនក្រហមហាណូយ បានបញ្ជារខ្មែរក្រហមបរិសុទ្ធ ការពារព្រំដែនខ្មែរ-យួន ខ្មែរ-សៀម ខ្មែរ-លាវ ឯណោះទៅវិញ ។ ចំណែកខ្មែរក្រហមហាណូយមួយចំនួនធំ ដែលជាបនបរិវាររបស់វៀតណាមយួនហា ណូយ បាននៅរៀបចំផ្ទៃក្នុងប្រទេសកម្ពុជា ។

ដូច្នេះការបញ្ជារថា: « បិទទ្វារព្រំដែន » មានន័យថា: « បិទច្រកព្រំដែន » សម្លាប់ពលរដ្ឋខ្មែរឲ្យអស់ សូម្បីតែខ្មែរ ណាម្នាក់ កុំឲ្យរត់ចេញក្រៅស្រុកបានឡើយ ។ គឺត្រូវតែសម្លាប់ខ្មែរឲ្យផុតពូជ « បើជីកស្មៅ ត្រូវជីកទាំងឫស » ។ ( នេះគឺជា សំដីរបស់មេបនប្រល័យពូជសាសន៍ វៀតណាមយួនក្រហមហាណូយ ) ។

ការបញ្ជារពី « អង្គការលើ » ថា: « ការពារព្រំដែនកម្ពុជា » គឺមានន័យចំពោះកងយុទ្ធមិត្តខ្មែរក្រហមបរិសុទ្ធដែល ស្រឡាញ់ គោរពមាតុភូមិរបស់ខ្លួន គឺពេញចិត្តនឹងស្លាប់ដើម្បីការពារជាតិ សាសនា និងបានបំពេញតួនាទីជាកុលបុត្រ កុលធី តាខ្មែរ គ្រប់លក្ខណៈដ៏ប្រសើរផងនោះ ។

ឱកាសដ៏ល្អកម្រមាននេះហើយ ដែល « អង្គការលើ » វៀតណាមយួនក្រហមហាណូយ បានបញ្ជារ « អង្គការចាត់ តាំង » របស់ខ្លួនយួនក្រហម ឱយបញ្ជារបនបរិវារខ្មែរក្រហមហាណូយ ដែលបានជ្រួតជ្រាបនូវគោលមាគ៌ានយោបាយបដិ វត្តន៍វៀតណាមយួនក្រហម និងបានស្ថិតក្រោមការបញ្ជារនៃ « អង្គការថ្នាក់លើនិងអង្គការចាត់តាំង » វៀតណាមយួនក្រ ហមហាណូយនោះឯង ។ ការបើក « យុទ្ធនាការបោសសំអាតកំទេចខ្មែរឲ្យផុតពូជ » បានប្រែក្លាយពាក្យថា « បោសសំអាត កំទេចខ្មាំង » ប្រឆាំង « អង្គការលើ » ប្រឆាំង « អង្គការបដិវត្តន៍ » ខ្មាំងសេអ៊ីអា ( CIA ) ចក្រព័ត្រអាមេរិក និងបនបរិវារ ក្បត់អង្គការ ។ តើដូចម្តេចទៅដែលហៅថា: « ខ្មាំងក្បត់អង្គការ ខ្មាំងសេអ៊ីអា ( CIA ) នោះ? » ។

ដោយការបិទទ្វារព្រំដែន និងបិទផ្លូវការទូតអន្តរជាតិ ដោយប្រើពាក្យថា: « ម្ចាស់ការឯករាជ » គឺមិនត្រូវការពឹងពាក់ បរទេសណានោះឡើយ ។ ពាក្យថា: « បិទទ្វារព្រំដែន » ក៏មិនខុសពីអត្ថន័យនៃពាក្យថា: « បិទទ្វារវាំងនន » នោះដែរ ។ បើ ប្រៀបធៀបនឹងរបប « កម្ពុជាប្រជាធិបតេយ្យ » និងពាក្យស្លោកស្របទៅតាមការអនុវត្តន៍ប្រល័យពូជសាសន៍ក្នុងរបបនោះ ប៉ុន្តែ ហួសសម័យដែលត្រូវយកពាក្យអស់ទាំងនោះ មកប្រើប្រមាទពលរដ្ឋខ្មែរបរិសុទ្ធ ក៏ដូចជាការប្រមាថអាយុជីវិតម្តាយឪ ពុករបស់ខ្លួន ក៏ដូចជាការប្រមាថសហគមអន្តរជាតិនោះដែរ ។

ព្រះពុទ្ធអង្គដែលជាព្រះជាម្ចាស់នៃពុទ្ធសាសនិកជនលើលោកនេះ បានសំដែងថា: អ្នកណាប្រមាថមាតាបិតារបស់ ខ្លួននោះ គឺត្រូវចុះនរកអន្តរិយកម្ម ។ ឯវិធីការពារខ្លួន គឺមិនមែនដោយការប្រមាថនោះឡើយ ។ គឺជាការប្រមាថអាយុជីវិត របស់ខ្លួន ធ្វើឱយផុយស្រួយទៅវិញនោះទេ ។

ព្រះពុទ្ធអង្គបានសំដែងថា: វិធីការពារខ្លួនឲ្យរឹងមាំ មានឈ្មោះពិរោះល្បី គឺត្រូវលះបង់តណ្ហាទាំងឡាយ រួចព្យាយាម

សាងនូវផ្លូវធម៌វិន័យ នៃព្រហ្មវិហារធម៌ទាំង៤ប្រការមាន: មេត្តា ករុណា មុទិតា ឧបេក្ខា គឺត្រូវមានក្ដីអាណិតអាសូរ អត់ឱនឲ្យគ្នាទៅវិញទៅមក ចំពោះអ្នកដទៃដែលទន់ខ្សោយ ទាំងចំណេះវិជ្ជា ទាំងទ្រព្យសម្បត្តិ ត្រូវចេះស្រឡាញ់ គោរព រាប់អានប្រជាជាតិរបស់ខ្លួន ក៏ដូចជាការស្រឡាញ់គោរពម្ដាយឪពុករបស់ខ្លួន ។ បើមានក្ដីអាណិត ស្រឡាញ់ គោរព ទើបមានការលះបង់បូជាការពារ ។ បើគ្មានក្ដីស្រឡាញ់គោរព គឺមិនមានការលះបង់បូជានោះឡើយ ។

មិនត្រូវច្រណែនអ្នកដទៃ ។ បើលោកផ្ដល់ក្ដីសុខជូនពលរដ្ឋខ្មែរ គឺត្រូវតែមានការតបស្នងនូវឧបការគុណយ៉ាងប្រពៃពីពលរដ្ឋខ្មែរ ។ តែបើលោកផ្ដល់ក្ដីលំបាក ទុក្ខសោកទឹកភ្នែកហូរឥតឈប់ឈរ និងថែមទាំងមានការប្រមាថឈឺចុកចាប់រាងកាយក្ដី ផ្លូវចិត្តក្ដី វិញនោះ សេចក្ដីអស់ទាំងនេះ ប្រាកដជាវិលត្រឡប់មករកអ្នកវិញមិនខាន ។ នេះគឺជាច្បាប់លោកបានចែងរួចមកហើយ ។

« ការបិទទ្វារព្រំដែន » ការបិទផ្លូវទំនាក់ទំនងអង្គការជាតិ- អន្តរជាតិក្ដី នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ ដូចជា: សេដ្ឋកិច្ច សារពត៌មានជាតិ អន្តរជាតិ ជាដើមនោះ ក៏ដូចជាការបំបិទសិទ្ធិសេរីភាពប្រជាជាតិខ្មែរ ទើបបណ្ដាលឲ្យមានការបើកកិច្ចប្រជុំមួយ នៃអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស ដើម្បីបើកកិច្ចសហអន្តរាគមន៍ត្រួតពិនិត្យសិទ្ធិមនុស្សជាបន្ទាន់នាថ្ងៃទី១៥ ខែមករាឆ្នាំ១៩៧៩នៅក្នុងប្រទេសកម្ពុជា ដើម្បីរំដោះសង្គ្រោះអាយុជីវិតពលរដ្ឋខ្មែរ ។ ពីព្រោះការ « បិទច្រកទ្វារព្រំដែន » គ្មានទំនាក់ទំនងអង្គការជាតិ អន្តរជាតិក្ដីនោះ គឺមានន័យថា: « បំបិទសិទ្ធិសេរីភាពពលរដ្ឋខ្មែរ » បិទទ្វារសម្លាប់ខ្មែរ បានប្រែក្លាយពាក្យថា: « បិទទ្វារវីឆ្នែ » ដោយការជេរប្រមាថអាយុជីវិតពលរដ្ឋខ្មែរប្រដូចទៅនឹងពេលវេលាដែលខ្លួនធ្លាប់បានអនុវត្តដោយ « អង្គការលើ » វៀតណាមយួនក្រហមហាណូយបានចាត់តាំងឲ្យខ្លួនអ្នកនិយាយពាក្យថា: « បិទទ្វារវីឆ្នែ » បានសម្លាប់ពលរដ្ឋខ្មែរនាសម័យ « កម្ពុជាប្រជាធិបតេយ្យ » ប្រល័យពូជសាសន៍ខ្មែរយ៉ាងងាយស្រួលបំផុតនោះ ។

« អង្គការលើ » វៀតណាមយួនក្រហមហាណូយ កាលបានដឹងអំពីគំរោងការណ៍របស់អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស មានគំរោងបើកកិច្ចសហប្រតិបត្តការត្រួតពិនិត្យស្ថានការណ៍នយោបាយនៅកម្ពុជានាថ្ងៃទី១៥ ខែមករាឆ្នាំ១៩៧៩នោះ ទើប « អង្គការលើ » វៀតណាមយួនក្រហមហាណូយវាតទីនិយម បានបញ្ជារឲ្យ « អង្គការចាត់តាំង » របស់ខ្លួនគឺយួនហាណូយ បង្កើត « អង្គការរណសិរ្ស » មួយនៅថ្ងៃទី២ ខែធ្នូ១៩៧៨ ។

« អង្គការរណសិរ្ស » បានបង្កើតឡើងតាមការបញ្ជាររបស់ « អង្គការលើ » និង « អង្គការចាត់តាំង » វៀតណាមយួនក្រហមវាតទីនិយម ដែលដឹកនាំដោយក្រុមខ្មែរក្រហមហាណូយ និងខ្មែរក្រហមយៀកមិញ ដែលមានលោកប៉ែន-សុវណ្ណ ជាប្រធានរណសិរ្ស២ធ្នូនោះឯង ។

រណសិរ្សនេះ ត្រូវបានបង្កើតឡើងនៅថ្ងៃទី២ខែធ្នូ ឆ្នាំ១៩៧៨ មានរយះពេល៦សប្ដាហ៍ប៉ុណ្ណោះ កម្ពុជាក៏ត្រូវបានកាន់កាប់ត្រួតត្រាដោយវត្តមានកងទ័ពឈ្លានពានប្រល័យពូជសាសន៍វៀតណាមយួនហាណូយ២០ម៉ឺននាក់នៅថ្ងៃទី៧មករាឆ្នាំ១៩៧៩ ដែលមានរយះពេលមុនមួយសប្ដាហ៍ប៉ុណ្ណោះ នៃវត្តមានអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស ត្រូវតែបើកកិច្ចសហអន្តរាគមន៍ត្រួតពិនិត្យស្ថានការណ៍នយោបាយស្ដីពីសិទ្ធិសេរីភាពនៅកម្ពុជានាថ្ងៃទី១៥ ខែមករាឆ្នាំ១៩៧៩ជាកំហិតនោះដែរ ។

ដូច្នេះការវាយប្រហារឈ្លានពានកម្ពុជា ពីសំណាក់កងទ័ពវៀតណាមយួនសង្គមនិយមវាតទី គឺហាក់បីដូចជាមានការងាយស្រួលឆាប់ពេករវាងសង្គ្រាមឈ្លានពានពីប្រទេសមួយទៅប្រទេសមួយនោះ ។ គឺមានន័យថា: « អង្គការលើ »

វៀតណាមយួនក្រហមហាណូយឈ្លានពានកម្ពុជា បានបង្កប់ពួកបនបរិវារខ្មែរក្រហមហាណូយនៅក្នុងផ្ទៃប្រទេសកម្ពុជា ផ្ទៃក្នុងជួរខ្មែរក្រហមបរិសុទ្ធរួចអស់ទៅហើយ ។ ដូច្នេះការកាន់កាប់ត្រួតត្រាកម្ពុជានាថ្ងៃទី១៧ខែមេសា ឆ្នាំ១៩៧៥ និងឧក្រិដ្ឋជនសង្គ្រាមប្រល័យពូជសាសន៍ខ្មែរអស់ជាង៣លាននាក់ គឺជាផែនការយុទ្ធសាស្ត្ររបស់ « អង្គការលើ » និង « អង្គការចាត់តាំង » របស់មេបនប្រល័យពូជសាសន៍វាតទីនិយមវៀតណាមយួនហាណូយឈ្លានពានកម្ពុជាទាំងអស់ ។ នេះគឺជា « យុទ្ធសាស្ត្រខ្ចីដៃខ្មែរសម្លាប់ខ្មែរ » ដូចការឈ្លានពានកម្ពុជានៅថ្ងៃទី៧មករា១៩៧៩ ទៅតាមគំរោងផែនការរបស់ខ្មោចហូ-ជីមិញបានរៀបចំ ។

គឺជា « យុទ្ធសាស្ត្រខ្ចីដៃខ្មែរសម្លាប់ខ្មែរដដែលៗជារៀងរហូត » ។ « អង្គការលើ » វៀតណាមយួនហាណូយ ហៅឈ្មោះថា: « យុទ្ធសាស្ត្រច្រេះស៊ីដែក » នោះឯង ។

ចំណែកសកម្មភាពនៃកងទ័ពយុទ្ធមិត្តខ្មែរក្រហមបរិសុទ្ធវិញនោះ បានខំប្រឹងតស៊ូប្ដេជ្ញាដាច់ខាត ការពារព្រំដែនខ្មែរ-យួន ខ្មែរ-សៀម និងខ្មែរ-លាវឯណោះទៅវិញ ។ រួចហើយ ក៏មានឈ្មោះជាឧក្រិដ្ឋជនសង្គ្រាម ត្រូវបានថ្កោលទោសពីមតិជាតិខ្មែរខ្លួនឯង និងអន្តរជាតិផងនោះទៅវិញ ។ ហ្នឹងហើយ គឺជា « យុទ្ធសាស្ត្រច្រេះស៊ីដែក » ដោយ « ខ្ចីដៃខ្មែរសម្លាប់ខ្មែរ ជាតិសាសន៍ដូចគ្នាក្នុងផ្ទៃប្រទេសកម្ពុជាដដែល » ។ ពាក្យចាស់បុរាណខ្មែរលោកបានពោលថា: « ស្វាស៊ីបាយ លាបមាត់ពពែ » នោះឯង ។

សូម្បីតែអតីតកងទ័ពវៀតណាមមួយចំនួនដែលបានរត់ចោលជួរកងទ័ពរបស់ខ្លួន ដែលមានមហិច្ឆិតាឈ្លានពានកម្ពុជានោះ ក៏បានដឹងអំពីឧបាយកលពិសពុលរបស់មេដឹកនាំវៀតណាមយួនហាណូយ ប្រើយុទ្ធសាស្ត្រខ្ចីដៃខ្មែរសម្លាប់ខ្មែរជំនួសយួនហាណូយនោះដែរ ។ មេបញ្ជាការវៀតណាមយួនហាណូយបាននិយាយថា: " វៀតណាមម្នាក់ត្រូវតែសម្លាប់ខ្មែរឲ្យបាន៣០នាក់ គ្រប់រូបភាពដោយរួមទាំងយុទ្ធសាស្ត្របំផ្លាញផងដែរ ។ គឺត្រូវតែសម្លាប់បំផ្លាញសេដ្ឋកិច្ចពលរដ្ឋខ្មែរជាកត្តាចម្បងនៅកម្ពុជា " ។

ថ្ងៃ៧មករា១៩៧៩ គឺជាថ្ងៃ « បើករបាំងមុខ » នៃមេបនប្រល័យពូជសាសន៍យួនក្រហមហាណូយ និងជាថ្ងៃឈ្លានពានកម្ពុជា បន្តវគ្គសម្លាប់ខ្មែរជាលើកទី២ក្នុង « យុទ្ធសាស្ត្រច្រេះស៊ីដែក » « ខ្ចីដៃខ្មែរសម្លាប់ខ្មែរ » គ្នាឯងបន្ត ។ បន្ទាប់ពីរបបប្រល័យពូជសាសន៍ថ្ងៃ១៧មេសា១៩៧៥ នោះឯង ។ ដូច្នេះផែនការរបស់ « អង្គការលើ » វៀតណាមយួនក្រហមហាណូយបានសម្លាប់ខ្មែរមានរយៈពេលជាង៣៦ឆ្នាំមកហើយ រហូតបច្ចុប្បន្នកាលនេះបន្ថែមទៀត តាមរយៈគណបក្សប្រជាជនកម្ពុជា ។

ថ្ងៃ៧មករា១៩៧៩ ដែលមានវត្តមានលោកប៉ែន-សុវណ្ណ ក៏ត្រូវបាន « អង្គការបក្ស » វៀតណាមយួនក្រហមហាណូយ តែងតាំងជានាយករដ្ឋមន្ត្រី ដោយការសម្រេចចិត្តពី « មជ្ឈឹមបក្ស » វៀតណាមយួនក្រហមហាណូយ នៅក្នុងរបប « សាធារណរដ្ឋប្រជាមានិតកម្ពុជា » កាន់កាប់ត្រួតត្រាដោយរដ្ឋអំណាចនៃមេបនប្រល័យពូជសាសន៍វៀតណាមយួនហាណូយវាតទីនិយម ឈ្លានពានកម្ពុជានោះឯង ។

លោកអតីតនាយករដ្ឋមន្ត្រី ប៉ែន-សុវណ្ណ ក្រោយពីបានដឹង បានយល់ អំពីជម្រៅនៃយុទ្ធសាស្ត្រឧបាយកលពិសពុលនៃមេបនប្រល័យពូជសាសន៍វាតទីនិយមវៀតណាមយួនហាណូយឈ្លានពានកម្ពុជានោះមក លោកប៉ែន-សុវណ្ណមានឆន្ទៈពីបំរះគេចចេញពីមហិច្ឆិតាឈ្លានពានវៀតណាមយួនហាណូយ ដោយយកលេសថ្ងៃ៧មករា១៩៧៩ ឈ្លានពានប្រល័យពូជសាសន៍ខ្មែរបន្ត ប្រែក្លាយជាថ្ងៃរំដោះសង្គ្រោះពលរដ្ឋខ្មែរ ក្នុងទ្រង់ទ្រាយបំភ័ន្តមតិជាតិខ្មែរនិងអន្តរជាតិប៉ុណ្ណោះ ។ ដូច្នេះ

លោកអតីតនាយករដ្ឋមន្ត្រីខ្មែរប៉ែន-សុវណ្ណ ត្រូវបាន « អង្គការបក្ស » វៀតណាមយួនហាណូយ ប្រកាសលិខិតចាប់ខ្លួនលោក នៅខែធ្នូឆ្នាំ១៩៨១ ដោយគ្រាន់តែមានវត្តមានសមមិត្តលោកហ៊ុន-សែន និងសមមិត្តសាយ-ប៊ូថងជាអ្នកអមដំណើរ និងជាអ្នកអានលិខិតរបស់ « អង្គការមជ្ឈឹមបក្ស » ចាប់ខ្លួនលោកអតីតនាយករដ្ឋមន្ត្រីខ្មែរប៉ែន-សុវណ្ណតែប៉ុណ្ណោះ ។

បន្ទាប់ពីបានចាប់ខ្លួនអតីតនាយករដ្ឋមន្ត្រីខ្មែរប៉ែន-សុវណ្ណ « អង្គការបក្ស » វៀតណាមយួនហាណូយ បានតែងតាំងលោកចាន់-ស៊ីដែលជាមនុស្សក្រុមរបស់លោកអតីតនាយករដ្ឋមន្ត្រីខ្មែរប៉ែន-សុវណ្ណ ឲ្យឡើងជានាយករដ្ឋមន្ត្រីជំនួសលោកប៉ែន-សុវណ្ណ ។ ដោយឆន្ទៈមនសិការ សម្បជញ្ញៈស្រឡាញ់ជាតិពិតប្រាកដ លោកអតីតនាយករដ្ឋមន្ត្រីខ្មែរចាន់-ស៊ីដែលមានជំហរស្មោះត្រង់ជាតិនិយមច្បាស់លាស់ ដោយមិនស្រពិចស្រពិលមិនខុសគ្នាពីលោកប៉ែន-សុវណ្ណដែរ ដោយមិនព្រមឱនក្បាលឲ្យ « អង្គការលើ » « អង្គការបក្ស » និង « អង្គការចាត់តាំង » វៀតណាមយួនហាណូយក្រហមលាងខួរក្បាលដើម្បីសម្លាប់ជាតិសាសន៍ខ្មែរខ្លួនឯង ដូចថ្ងៃ១៧មេសា១៩៧៥ « របបកម្ពុជាប្រជាធិបតេយ្យនោះទេ » ។ លោកអតីតនាយករដ្ឋមន្ត្រីខ្មែរចាន់-ស៊ីក៏បានសុខចិត្តបូជាជីវិតក្នុងបុព្វហេតុដ៏ត្រឹមត្រូវក្នុងនាមជាអ្នកដឹកនាំខ្មែរដ៏មានវីរភាពអង់អាចក្លាហាន ហ៊ានទទួលខុសត្រូវចំពោះប្រវត្តិសាស្ត្រ ដោយមិនព្រមបូជាជាតិខ្មែរខ្លួនឯងនោះទេ ។

លោកអតីតនាយករដ្ឋមន្ត្រីខ្មែរចាន់-ស៊ី ក៏ត្រូវបាន « អង្គការលើ » វៀតណាមយួនហាណូយក្រហម ចាក់ថ្នាំសម្លាប់នៅក្នុងមន្ទីរពេទ្យទីក្រុងមូស្គូប្រទេសរុស្ស៊ី នៅចុងឆ្នាំ១៩៨៤ ។

បន្ទាប់មក « អង្គការបក្ស » វៀតណាមយួនក្រហម បានសម្លឹងឃើញមនុស្សម្នាក់ទៀត ដែលមានមហិច្ឆិតាស្រឡាញ់ចូលចិត្តអំណាចតាំងតែពីវ័យកុមារភាពនោះ គឺសមមិត្តហ៊ុន-សែន ក៏ត្រូវបាន « អង្គការបក្ស » វៀតណាមយួនក្រហម តែងតាំងជានាយករដ្ឋមន្ត្រីត្រួតត្រាខ្មែរបន្តជំនួសវៀតណាមយួនក្រហម នៅខែមករាឆ្នាំ១៩៨៥ ។

សមមិត្តនាយករដ្ឋមន្ត្រីត្រួតត្រាខ្មែរ បានសច្ចាប្រណិធានចំពោះមុខ « អង្គការបក្ស » វៀតណាមយួនក្រហមថា: " ខ្លួននឹងប្តេជ្ញាដើរតាមគោលមាគ៌ានយោបាយរបស់ « អង្គការលើ » « អង្គការបក្ស » និង « អង្គការចាត់តាំង » វៀតណាមយួនក្រហមជារៀងរហូត ដោយមិនធ្វើដូចសមមិត្តបងៗទាំងពីរនាក់មុនៗនោះឡើយ " ។ អង្គការទាំង៣វៀតណាមយួនក្រហមបានចាប់ឱបនាយករដ្ឋមន្ត្រីហ៊ុន-សែនយ៉ាងកក់ក្តៅ ថែមទាំងបានសន្យាថា: " តូតឡាំៗ ( ល្អណាស់ៗ ) សមមិត្តត្រូវតែក្លាយខ្លួនជានាយករដ្ឋមន្ត្រី ត្រួតត្រាខ្មែរអស់មួយជីវិត " ។

ថ្ងៃ៧មករា១៩៧៩ ដែលកងទ័ពវៀតណាមយួនក្រហមបានឈ្លានពានកម្ពុជាដោយឧបាយកលពិសពុល ក្នុង « សង្គ្រាមយុទ្ធសាស្ត្រ ខ្ទីដៃខ្មែរសម្លាប់ខ្មែរ » បន្ត ហៅថា: « យុទ្ធសាស្ត្រច្រេះស៊ីដែក » ។ ក្រោយថ្ងៃ១៧មេសា ១៩៧៥ ដោយអនុវត្ត « យុទ្ធសាស្ត្រឈ្នះៗ » ដដែលៗ សម្លាប់ខ្មែររហូតបច្ចុប្បន្នភាពនេះ ។

ក្រោយថ្ងៃ៧មករា១៩៧៩ ដោយវត្តមានកងទ័ពវៀតណាមយួនក្រហមចាប់បង្ខំ ចំនួន២០ម៉ឺននាក់ ឈ្លានពានកម្ពុជានោះ ត្រូវបានថ្កោលទោសយ៉ាងពេញទំហឹងពីសហគមអន្តរជាតិ រួមទាំងពលរដ្ឋខ្មែរ បានក្រោកឈរឡើងបង្កើតចលនាខ្មែរតស៊ូប្រដាប់អាវុធ ប្រឆាំងបណ្តេញកងទ័ពវៀតណាមយួនក្រហមឈ្លានពានកម្ពុជា ដោយរួមទាំងកងកម្លាំងយុទ្ធមិត្តខ្មែរក្រហមបរិសុទ្ធ ដែលដឹកនាំដោយលោកសាឡុត-ស ( យួនហៅប៉ុល-ពត ) លោកខៀវ-សំផន លោកតាម៉ុក-ជាដើមនោះ ។ ដូច្នេះថ្ងៃ៧មករា១៩៧៩ គឺមិនមែនជាថ្ងៃរំដោះសង្គ្រោះកម្ពុជា ឱយផុតពីរបបប្រល័យពូជសាសន៍ ដូចការលើកឡើងរបស់គណបក្សប្រជាជនកម្ពុជា ដោយគ្រាន់តែយកបប្តូរមាត់ « អង្គការបក្ស » វៀតណាមយួនក្រហម មកឃោសនាជំនួសដើម្បីបំភ័ន្តមតិជាតិខ្មែរ និងអន្តរជាតិប៉ុណ្ណោះ ។

ថ្ងៃ៧មករា១៩៧៩ គឺជាថ្ងៃបន្តរបបប្រល័យពូជសាសន៍បែបថ្មី នៃវៀតណាមយួនក្រហមវាតទីនិយមឈ្លានពានកម្ពុជា បន្ទាប់ពី « របបប្រល័យពូជសាសន៍ជាក់ស្តែង » ថ្ងៃ១៧មេសា១៩៧៥ នោះឯង ។ ពាក្យចាស់បុរាណខ្មែរលោកបានពោលថា: " គោចាស់ផ្លាស់គន្លងថ្មី " សម្រាប់ខ្មែរ គឺនៅតែសម្លាប់បន្ត « ចូរខ្មែរកុំប្រហេស ខ្លាចបាត់ដី ខ្មែរភ្ញាក់ស្មារតី ជាតិរស់គង់វង់ » ។

របបប្រល័យពូជសាសន៍ថ្ងៃ១៧មេសា១៩៧៥ គឺជា « របបប្រល័យពូជសាសន៍បែបជាក់ស្តែង » ។ របបប្រល័យពូជសាសន៍ថ្ងៃ៧មករា១៩៧៩ គឺជា « សង្គ្រាមប្រល័យពូជសាសន៍បែបទំនើប » ក្នុងសតវត្សទី២១នេះ ។

ចលនាខ្មែរ ត ស៊ូប្រដាប់អាវុធ ដែលមានមូលដ្ឋាននៅតាមបណ្តោយព្រំដែនខ្មែរ-ថៃ មាន៣ប្រមុខដឹកនាំៈ

១- ចលនាខ្មែរតស៊ូប្រដាប់អាវុធ មានឈ្មោះហៅថា: « ហ្វ៊ុនស៊ិនប៉ិច » ដែលដឹកនាំដោយព្រះមហាក្សត្រព្រះបាទនរោត្តមស៊ីហនុ ។

២- ចលនាខ្មែរតស៊ូប្រដាប់អាវុធ ដែលដឹកនាំដោយសម្តេចស៊ឺនសាន មានឈ្មោះហៅថា: « រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ » ។

៣- និងកងកម្លាំងប្រដាប់អាវុធយុទ្ធមិត្តខ្មែរក្រហមបរិសុទ្ធ មានឈ្មោះហៅថា: « ខ្មែររំដោះជាតិកម្ពុជា » ដែលដឹកនាំដោយលោកសាឡុត-ស ( យួនហៅប៉ុល-ពត ) លោកខៀវ-សំផន តាម៉ុកជាដើមនោះ ។

មានប្រទេសមហាអំណាចពីរគឺ: សហរដ្ឋអាមេរិក- សាធារណរដ្ឋប្រជាមានិតចិន បានផ្តល់ជំនួយសម្ភារះសឹកសំរាប់កងកម្លាំងខ្មែរតស៊ូទាំង៣ប្រមុខដឹកនាំ និងរួមទាំងអង្គការមនុស្សធម៌ជាច្រើនទៀត បានចូលរួមផ្តល់ស្បៀងអាហារសំរាប់ជនភៀសខ្លួនខ្មែររាប់ម៉ឺនសែននាក់ ដែលបានភៀសខ្លួនចេញពីកម្ពុជា ទៅជ្រកកោននៅក្នុងជំរុំខ្មែរអ្នកតស៊ូទាំងនោះ ។ គឺដោយសារការភ័យខ្លាចរបបប្រល័យពូជសាសន៍វគ្គទី២ និងភ័យខ្លាចសង្គ្រាមពីសំណាក់កងទ័ពវៀតណាមយួនក្រហមឈ្លានពានកម្ពុជា ពើបប្រយុទ្ធជាមួយកងកម្លាំងប្រដាប់អាវុធតស៊ូខ្មែរទាំង៣ប្រមុខដឹកនាំ ដើម្បីរំដោះសង្គ្រោះកម្ពុជាដែលជាមាតុប្រទេសរបស់ខ្លួន ក្នុងការបំពេញកាតព្វកិច្ចជាកុលបុត្រ កុលធីតាខ្មែរ កត្តញ្ញូ នៃឧបការគុណនៃមាតុភូមិកំណើតរបស់ខ្លួន ។ ត្រូវតែប្រយុទ្ធ ការពារ ថែរក្សា ទឹកដី សិទ្ធិសេរីភាព ពលរដ្ឋខ្មែរ ។ ការអនុវត្តន៍នៃសកម្មភាពបែបនេះ គឺជាប្រពៃណីវប្បធម៌ នៃកុលបុត្រកុលធីតាខ្មែរគ្រប់តំណរៀងមក ។

រដ្ឋាភិបាលវៀតណាមយួនក្រហម បានបោកបញ្ឆោត និងចាប់បង្ខំយុវជនយុវនារីវៀតណាមរាប់ម៉ឺនសែននាក់បញ្ជូនទៅច្រូតកាត់ប្រមូលផលស្រូវនៅកម្ពុជា ដោយមេដឹកនាំវៀតណាមយួនក្រុងហាណូយ បានភូតភរប្រជាជនខ្លួនឯងថា: " ដោយការដឹងគុណរបស់ប្រជាជនកម្ពុជានាថ្ងៃ៧មករា១៩៧៩ និងជាមិត្តភាពរាប់ម៉ឺនឆ្នាំទៀតផងនោះ ទើបប្រជាជនកម្ពុជាប្រគល់ស្រូវអង្ករ ភោគផលធម្មជាតិផ្សេងៗ ជួយប្រជាជនវៀតណាមវិញ ដូចជាព្រៃឈើ សម្បទានដីសំរាប់ប្រជាជនវៀតណាម អាចចូលទៅរស់នៅលើទឹកដីកម្ពុជាបានដោយសេរីទៀតផង ពីព្រោះកម្ពុជាសម្បូណ៌ភោគផលធម្មជាតិសម្បើមណាស់ ។ ដីធំទូលំទូលាយ ប្រជាជនកម្ពុជាមានចំនួនតិច ។ ទឹកដីកម្ពុជា មានមាសដុះស្អេកស្កះពេញព្រៃ ប្រជាជនវៀតណាមយើងកាប់ព្រៃឈើអស់ ជីកដីវាររករ៉ែមាសទៀត " ។ ( នេះគឺជាសំដីរបស់មេបនប្រល័យពូជសាសន៍វៀតណាមយួនហាណូយក្រហម ប្រើនយោបាយចិត្តសាស្ត្រប្រជាភិថុបោកប្រាស់ប្រជាជនខ្លួនឯង ) ។

តែទីបំផុត ក្រុមយុវជនវៀតណាមទាំងអស់នោះ បានភ្ញាក់ខ្លួនព្រើតគ្រប់ៗគ្នា ។ ពេលឈានជើងចូលដល់ទឹកដីខ្មែរខណៈនោះមេបញ្ជារការវៀតណាមយួនក្រហម បានបោះសម្លៀកបំពាក់យោធាសម្ភារះសឹកដូចជា កាំភ្លើង ប៉ែល សំរាប់ជីក

របណ្ដៅត្រៀមប្រយុទ្ធ អង្រឹងសំរាប់ដេកជាដើម ដែលមិនមែនជាឧបករណ៍សំរាប់ច្រូតកាត់ប្រមូលផលនោះ ។

មេបញ្ជាការវៀតណាមយួនក្រហម ថែមទាំងបានគំរាមចំពោះយុវជនវៀតណាមទាំងអស់នោះថាៈ " បើមានអ្នកណាម្នាក់រត់ចោលជួរកងទ័ព បើអង្គការចាប់បាន ត្រូវបាញ់ចោល រួចហើយត្រូវចាប់ឪម៉ែ សាច់ញាតិបងប្អូននៅឯស្រុក ដាក់គុកទាំងពូជទៀតផង " និងហាមបញ្ជូនដំណឹងទៅប្រាប់សាច់ញាតិថាៈ " កូនចៅធ្វើសង្គ្រាមនៅកម្ពុជា " ។ ត្រូវតែនិយាយថាៈ " កូនចៅសុខសប្បាយជាធម្មតាទេ " ។ កម្ពុជាសម្បូណ៌សប្បាយណាស់ ថ្ងៃក្រោយ " ឪម៉ែ បងប្អូន ត្រូវមករស់នៅជាមួយកូនចៅនៅកម្ពុជា " ។

ការបង្គាប់បញ្ជារពី « អង្គការលើ » នៃមេដឹកនាំយួនក្រហមហាណូយ ឲ្យយុវជនវៀតណាមនិយាយភាសារតែមួយដូចៗគ្នា ក៏មិនខុសអំពី « អង្គការលើ » នៃវៀតណាមយួនក្រហម បង្គាប់បញ្ជារឲ្យគណបក្សប្រជាជនកម្ពុជាដែលជារដ្ឋាភិបាលកូនអុករបស់ខ្លួននៅកម្ពុជាបច្ចុប្បន្ន អនុវត្តន៍គោលមាគ៌ានយោបាយ នៃខ្សែបន្ទាត់របស់ « អង្គការបក្ស » វៀតណាមយួនក្រហម និងនិយាយភាសាទន្ទេញដូចៗតែគ្នានោះដែរ ។

សង្គ្រាមទ័ពព្រៃនៃចលនាខ្មែរតស៊ូប្រដាប់អាវុធទាំង៣ប្រមុខដឹកនាំ បានបើកយុទ្ធនាការវាយប្រហារយ៉ាងខ្លាំងក្លាតាមក្បួនយុទ្ធសាស្ត្រប្រឡេះគ្រាប់ពូជវៀតណាមយួនក្រហមឈ្លានពានកម្ពុជា ដោយយុទ្ធសាស្ត្រវាយឆ្មក់សត្រូវឥតឈប់ឈររៀងរាល់ថ្ងៃ ស្ទើរតែគ្រប់តំបន់ នៅក្នុងផ្ទៃប្រទេសកម្ពុជា ។

សូមបញ្ជាក់ផងដែរថាៈ មេបញ្ជាការវៀតណាមយួនក្រហម បានបង្ហាត់ហ្វឹកហ្វឺនក្បួនយុទ្ធសាស្ត្រលើសមរភូមិ ចំពោះយុវជនវៀតណាម មានរយៈពេលប្រមាណ៥សប្ដាហ៍ប៉ុណ្ណោះ ។

ចំពោះរាល់ឧបាយកលរបស់ « អង្គការលើ » នៃវៀតណាមយួនក្រហម ដែលបានបោកបញ្ឆោតបង្ខំកូនចៅរបស់ប្រជាជនខ្លួនឯងដើម្បីឈ្លានពានកម្ពុជានាថ្ងៃ៧មករា១៩៧៩នោះ គឺមិនមែនការស្ម័គ្រចិត្តនៃកងទ័ពវៀតណាមដូចការលើកឡើងរបស់គណបក្សប្រជាជនកម្ពុជា តែងតែនិយាយជំនួសបបូរមាត់ « អង្គការលើ » នៃវៀតណាមយួនក្រហមបានបង្គាប់បញ្ជារទាំងអស់នោះទេ ។

កងយុវជនវៀតណាមទាំងអស់នោះ កាលបើបានកាន់អាវុធគ្រប់ដៃដោយការបោកបញ្ឆោតពីមេដឹកនាំរបស់ពួកគេ ក៏អស់ក្ដីសង្ឃឹមក្នុងឆាកជីវិតរៀងៗខ្លួនថាៈ " មិនដឹងថ្ងៃណាអាចវិលជួបមុខឪម៉ែឯស្រុកបានទេ " ។

កងទ័ពវៀតណាមដោយចាប់បង្ខំទាំងអស់នោះ បានតែងតែច្រៀងនូវចម្រៀងក្រោមចំណងជើងថាៈ " សម្លេងផ្ដែផ្ដាំនៃជីវិតចុងក្រោយរបស់កូន " ។ កងទ័ពវៀតណាមទាំងអស់នោះ ស្រែកច្រៀងដើម្បីបំបាត់ការភ័យខ្លាចផង និងក្ដីនឹករលឹកក្រុមគ្រួសារផង ។ ច្រៀងបណ្ដើរ ទឹកភ្នែកហូរបណ្ដើរ ថែមទាំងបានបង្កើរពាក្យ២-៣ម៉ាត់ចុងបញ្ចប់នៃចម្រៀងថាៈ " មិនដឹងថ្ងៃណាកូនបានជួបមុខឪម៉ែ កូនងាប់ហើយ កូនលាហើយ " ។

ដូច្នេះចំណុចខ្សោយ « អង្គការលើ » នៃមេបនប្រល័យពូជសាសន៍វៀតណាមយួនក្រហមវាតទីនិយមឈ្លានពានកម្ពុជា មាន៥ចំណុចសំខាន់ៗគឺៈ

ចំណុចទី១ៈ ដោយមានការថ្កោលទោសពីសហគមអន្តរជាតិ នៃការឈ្លានពានបន្តរបបប្រល័យពូជសាសន៍ នាថ្ងៃ៧មករា១៩៧៩ ។

ចំណុចទី២ៈ ដោយសារមេក្លោងកំណាចរុស្ស៊ីដែលបានគាំទ្រមហិច្ឆិតា « អង្គការលើ » នៃវៀតណាមយួនក្រហមឈ្លានពានកម្ពុជា បានជួបវិបត្តិសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ង ដូច្នេះរុស្ស៊ីមិនអាចបំពេញមហិច្ឆិតានៃមេដឹកនាំវៀតណាមយួនក្រហម

ហាណូយ តាំងមូលដ្ឋានទ័ពនៅលើទឹកដីកម្ពុជា លេបត្របាក់កម្ពុជា ដើម្បីឈានទៅរកការឈ្លានពានប្រទេសដទៃទៀតផ្សេងទៀតនោះបានឡើយ ។ ពីព្រោះរុស្ស៊ី ត្រូវចំណាយថវិការសំរាប់កងទ័ពវៀតណាមយួនហាណូយនៅកម្ពុជា អស់៣លានដុល្លាសហរដ្ឋអាមេរិកក្នុងមួយថ្ងៃៗ ទាំងសម្ភារៈសឹក ឱសថព្យាបាល រួមទាំងស្បៀងអាហារផងនោះ ។

ចំណុចទី៣: គឺរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន បានបាញ់គ្រាប់ផ្លោងរាប់ពាន់គ្រាប់ចូលក្នុងទឹកដីវៀតណាមយួនហាណូយ ។ ចំណែករាជរដ្ឋាភិបាលថៃវិញ ក៏បានបាញ់គ្រាប់ផ្លោងរាប់រយគ្រាប់ផងដែរ ។ គឺបាញ់តម្រង់គោលដៅទីតាំងកងទ័ពវៀតណាមយួនហាណូយ នៅចំណុចខ្សែត្រៀមតាមបណ្តោយព្រំដែនខ្មែរ-ថៃ ដើម្បីការពារខ្សែក្រវ៉ាត់ប្រទេសថៃផងក៏ដូចជាការការពារមូលដ្ឋាននៃចលនាខ្មែរតស៊ូផងដែរ ។

ចំណុចទី៤: គឺកងទ័ពខេមរភូមិន្ទរបស់លោកអតីតនាយករដ្ឋមន្ត្រីខ្មែរប៉ែន-សុវណ្ណ ចាន់-ស៊ី មួយចំនួនធំ ដែលនៅធ្វើការជាមួយកងទ័ពវៀតណាមយួនហាណូយ ប៉ុន្តែបំរើផលប្រយោជន៍ជាតិខ្មែរនោះ ។ ពេលពើបប្រទះជាមួយកងកម្លាំងប្រដាប់អាវុធតស៊ូខ្មែរទាំង៣ប្រមុខដឹកនាំនៅក្នុងព្រៃ ខ្មែរយើងមិនប្រយុទ្ធគ្នាជាដាច់ខាត គឺខ្មែរយើងបានរត់គេចតែរៀងៗខ្លួន ។

ចំណុចទី៥: នៃមេបនប្រល័យពូជសាសន៍វៀតណាមយួនក្រហមយ៉ាងធ្ងន់ធ្ងរបន្ថែមទៀតនោះគឺ ប្រជាជនវៀតណាមបានស្រែកទ្រហ៊ោយំអឺងកងរំពង នៅចំពោះមុខរដ្ឋាភិបាលវៀតណាមយួនក្រហមក្រុងហាណូយ ទាមទារសុំឲ្យសងជីវិតកូនចៅរបស់ពួកគេទាំងអស់មកវិញ ដែលបានស្លាប់រាប់រយក្បាលក្នុងមួយថ្ងៃៗនៅលើទឹកដីខ្មែរ ។ ពីព្រោះកូនចៅរបស់ពួកគេដែលជាយុវជន យុវនារី ជំនាន់ក្រោយៗ មិនមានមហិច្ឆិតាឈ្លានពានក្នុងការបង្កើតអរិភាពរវាងប្រទេសជិតខាងណាមួយនោះឡើយ ។

ដូច្នេះរដ្ឋាភិបាលយួនក្រុងហាណូយ មានការព្រួយបារម្ភយ៉ាងខ្លាំងបន្ថែមទៀត ពីការស្រែកទ្រហ៊ោរយំទាមទារនូវសំណងជីវិតកូនចៅនៃប្រជាជនវៀតណាម ដែលជាអ្នករស់នៅក្រោមដំបូលអំណាច នៃរដ្ឋាភិបាលយួនក្រុងហាណូយខ្លួនឯងនោះទៀតផង ។ ចំណែកប្រជាពលរដ្ឋខ្មែរ ក៏មិនសប្បាយចិត្តចំពោះវត្តមានកងទ័ពវៀតណាមយួនហាណូយឈ្លានពានកម្ពុជា និងរួមទាំងវត្តមានជនអន្តោប្រវេសន៍ខុសច្បាប់ នៃប្រជាជនវៀតណាមរាប់លាននាក់ រស់នៅលើទឹកដីខ្មែរនោះដែរ ។

ចំណុចខ្សោយនៃរដ្ឋាភិបាលវៀតណាមយួនក្រុងហាណូយទាំង៥ចំណុចខាងលើនេះ ហើយទើបបណ្តាលឲ្យមេដឹកនាំវៀតណាមយួនក្រុងហាណូយ សុំជួបចរចារជាសម្ងាត់ជាមួយប្រធាននៃចលនាខ្មែរតស៊ូប្រដាប់អាវុធទាំង៣ប្រមុខដឹកនាំ គឺព្រះមហាក្សត្រព្រះបាទនរោត្តមសីហនុ ជាប្រមុខដឹកនាំនោះឯង ។ នេះហើយហៅថា: « យុទ្ធសាស្ត្រនយោបាយទាល់ច្រកចរចារ ពេលណាមេបនប្រល័យពូជសាសន៍វៀតណាមយួនក្រុងហាណូយ ត្រូវបានទទួលការបរាជ័យ ដោយចាញ់កលនៃកុលបុត្រ កុលធីតាខ្មែរដោយប្រការណាមួយនោះ » ។

ដូច្នេះ ចូរខ្មែរគ្រប់ៗរូបគ្រប់ជំនាន់ ត្រូវតែចងចាំ គឺមិនត្រូវចរចារដោយសន្តិវិធី ជាមួយសត្វក្រពើវៀតណាមយួនក្រុងហាណូយជាដាច់ខាត ។

ក្រោយកិច្ចជំនួបចរចាររវាងព្រះមហាក្សត្រព្រះបាទនរោត្តមសីហនុ និងមេដឹកនាំវៀតណាមយួនក្រុងហាណូយ ដោយសម្ងាត់បានសម្រេចតាមបំណងយល់ស្របគ្នាទាំងសងខាងនោះមក ទើបមេដឹកនាំរដ្ឋាភិបាលវៀតណាមយួនក្រុងហាណូយ បានបញ្ជូនបេសកជនពិសេសដែលជាឧបករណ៍របស់ខ្លួន គឺសមមិត្តនាយករដ្ឋមន្ត្រីហ៊ុន-សែន ឲ្យទៅចរចារជាមួយព្រះមហាក្សត្រព្រះបាទនរោត្តមសីហនុ ដែលជាប្រធាននៃចលនាខ្មែរតស៊ូនៅទីក្រុងប៉ារីសប្រទេសបារាំង ជំនួសមុខមេដឹកនាំវៀតណាមយួនក្រុងហាណូយ ដែលជា « អង្កការលើ » នៃគណបក្សប្រជាជនកម្ពុជានោះវិញ ។

ដោយមានការជ្រោមជ្រែងយ៉ាងសកម្មពីសហគមអន្តរជាតិផងនោះ ដោយបានឃើញអ្នកដឹកនាំរដ្ឋាភិបាលអំណាចយួនក្រុងហាណូយនៅកម្ពុជា មានឆន្ទះបង្រួបបង្រួមជាតិ ស្វែងរកសន្តិភាពជូនប្រជាជាតិខ្មែរនោះ ទើបមានកិច្ចមហាសន្និបាតអន្តរជាតិមួយនៅទីក្រុងប៉ារីសប្រទេសបារាំង ស្តីអំពីសន្តិភាពនៅកម្ពុជានាថ្ងៃទី២៣តុលាឆ្នាំ១៩៩១ ។ ដោយសហគមអន្តរជាតិមានការព្រួយបារម្ភខ្លាចខ្មែរស្លាប់ដូចរបបប្រល័យពូជសាសន៍ កម្ពុជាប្រជាធិបតេយ្យបន្តបែបថ្មីទាន់សម័យបន្ថែមទៀតនោះ ។ ពីព្រោះខ្លាចដាច់ពូជខ្មែរ ទើបមានបណ្តាប្រទេសមហាអំណាចជាច្រើន បានចូលរួមជាសមាជិកដែលសរុបទាំងអស់មាន១៩ប្រទេស ដោយបូកបញ្ចូលទាំងប្រទេសកម្ពុជាមួយទៀតនោះ បានចុះហត្ថលេខាគាំទ្រជួយផ្នែកសេដ្ឋកិច្ចពលរដ្ឋខ្មែរឲ្យជៀសផុតពីភាពក្រីក្រ និងធានារ៉ាប់រងការពារឯករាជ្យជាតិ អធិបតេយ្យភាព សន្តិភាពសិទ្ធិសេរីភាព និងភាពមិនអាចរំលោភឈ្លានពានបូរណភាពដែនដីកម្ពុជាពីបរទេសណាមួយនោះបានឡើយ និងមានការបោះឆ្នោតដោយ សេរីយុត្តិធម៌ ដោយយកសម្លេងពលរដ្ឋខ្មែរជាធំ ដើម្បីជ្រើសរើសអ្នកដឹកនាំវាសនាជាតិខ្មែរដោយខ្លួនឯង គឺមិនត្រូវទទួលស្គាល់អ្នកដឹកនាំណាដែលត្រូវបានតែងតាំង ឬចាត់តាំងបន្តុបពី « អង្គការចាត់តាំង » វៀតណាមយួនហាណូយក្រហមនោះឡើយ ។

ក្រោយពីបានបញ្ចប់សង្គ្រាមរវាងចលនាខ្មែរតស៊ូប្រដាប់អាវុធ និងរដ្ឋាភិបាលនៃគណបក្សប្រជាជនកម្ពុជារដ្ឋអំណាចវៀតណាមយួនក្រុងហាណូយ ដោយសារតែកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសប្រទេសបារាំងនោះមក រដ្ឋាភិបាលនៃរដ្ឋអំណាចក្រុងហាណូយនៅកម្ពុជា បានអនុវត្តគោលមាគ៌ានយោបាយឈ្នះៗបន្តទៀត តាមបញ្ជារបស់ « អង្គការលើ » វៀតណាមយួនក្រហមទាំងអស់ ។ គឺត្រូវតែរំលាយមូលដ្ឋាននៃចលនាខ្មែរតស៊ូប្រដាប់អាវុធនៅតាមព្រំដែនខ្មែរ-ថៃ ត្រូវតែរំសាយកងទ័ពចលនាខ្មែរតស៊ូប្រដាប់អាវុធមួយចំនួន ត្រូវតែដុតកំទេចអាវុធចោលជាដើម ។

កម្ពុជាក៏បានប្រែក្លាយមុខមាត់សារជាថ្មីម្តងទៀត គឺដោយសារកិច្ចព្រមព្រៀងសន្តិភាពស្តីពីកម្ពុជា ថ្ងៃទី២៣តុលាឆ្នាំ១៩៩១នៅប្រទេសបារាំងនោះ គឺពិតជាត្រូវបានទទួលស្គាល់ពីមតិជាតិខ្មែរ និងឆាកអន្តរជាតិ ព្រមទាំងបានចំណាយថវិការាប់រយពាន់លានដុល្លាសហរដ្ឋអាមេរិកក្នុងមួយឆ្នាំៗ ពីសហគមអន្តរជាតិសំរាប់ពលរដ្ឋខ្មែរទៀតផង ។

ចំណែកអ្នកដឹកនាំរដ្ឋាភិបាលរដ្ឋអំណាចវៀតណាមយួនក្រហមនៅកម្ពុជា ក៏បានប្រែក្លាយមុខមាត់ពីរបបសមមិត្តផ្លាស់ប្តូរទៅជានាយករដ្ឋមន្ត្រី ឧបនាយក ឯកឧត្តម ជំទាវតូច ជំទាវជំទើ ជំទាវធំ មន្ត្រីឧញ៉ា សេនាបតី មានផ្កាយកូនមាន់ ផ្កាយកូនចោរ ផ្កាយមេចោរព្រោងព្រាតជាដើមនោះ គឺតាមការអនុវត្តន៍របស់ « អង្គការលើ » នៃវៀតណាមយួនក្រហមដែលជាមេការដាំស្ល និងជាសេនារិយោអ្នកដឹកនាំសាច់រឿងផង ត្រូវបញ្ជារឲ្យអ្នកណាម្នាក់សំដែងតួអង្គជាយក្ស ជាស្តេច ឬជាអាមាត្យ គឺតាមការចាត់តាំងពីថ្នាក់លើ អង្គការលើវៀតណាមយួនក្រហមទាំងអស់ ។ គឺដោយសារតែការដាក់អាវុធចុះបង្រួបបង្រួមជាតិ តាមព្រះរាជបន្ទូលព្រះប្រធានពរេត្តមស៊ី-ហនុ ប្រមុខដឹកនាំចលនាខ្មែរតស៊ូប្រដាប់អាវុធ និងដោយការចរចារជាមួយ « អង្គការលើ » រដ្ឋាភិបាលវៀតណាមយួនក្រហម ទើបបណ្តាលឲ្យមានកិច្ចព្រមព្រៀងថ្ងៃ២៣តុលា១៩៩១ ស្តីពីសន្តិភាពនៅកម្ពុជា ។

ដូច្នេះ « អង្គការលើ » វៀតណាមយួនក្រហម បានដើរតួជាមេបាថែចូវនាំឲ្យមាន២៣តុលា១៩៩១នេះផង និងជាមេឧក្រិដ្ឋជនប្រល័យពូជសាសន៍វាតទីនិយមឈ្លានពានកម្ពុជាផង បានសម្លាប់ថ្ងៃ២៣តុលា១៩៩១ផង ក៏ដូចជាការប្រល័យពូជសាសន៍ខ្មែរ ក្នុងឧបាយកលនៃយុទ្ធសាស្រ្តឈ្នះៗ « ខ្ញីដៃខ្មែរសម្លាប់ខ្មែរ » បន្តផង ដោយយុទ្ធសាស្រ្តចរចារបង្រួបបង្រួមជាតិភាសាជដែលៗនេះឯង ។

សូមរំលឹកផងដែរថា: ការបង្រួបបង្រួមជាតិខ្មែរនេះហើយ នៅថ្ងៃ១៧មេសា១៩៧៥ បណ្តាលឲ្យខ្មែរស្លាប់អស់ជាង៣

លានធាក់ ក្នុង « របបកម្ពុជាប្រជាធិបតេយ្យ » ។ ការបង្រួបបង្រួមជាតិថ្ងៃទី២៣តុលា១៩៩១ បណ្តាលឲ្យខ្មែរស្លាប់អស់ទាំងជីវិតមនុស្ស សត្វ សម្បត្តិធម្មជាតិ ព្រៃឡង់ជាដើម ។ ល ។ ក្នុងការប្រល័យពូជសាសន៍លើកទី២នេះ គឺសម្លាប់ខ្មែរបោសលានតែម្តងតាមគោលការណ៍នយោបាយឈ្លះៗរបស់ « អង្គការលើ » វៀតណាមយួនក្រហមតាមរយៈគណបក្សប្រជាជនកម្ពុជា គឺនៅក្នុង «របប សាធារណរដ្ឋប្រជាមានិតកម្ពុជា » ប្រែក្លាយជា « របបព្រះរាជាណាចក្រកម្ពុជា » សព្វថ្ងៃនេះ គឺសម្លាប់ខ្មែរខ្លាំងជាងមុនឆ្ងាយណាស់ បើប្រៀបប្រដូចនឹង « របបកម្ពុជាប្រជាធិបតេយ្យ » សម្លាប់ខ្មែរដោយប្រើត្បូងចបគល់ឬស្សីជាដើមនោះ ។

រដ្ឋអំណាចវៀតណាមយួនក្រហមនៅកម្ពុជា បានកំពុងអនុវត្តគោលការណ៍នយោបាយឈ្លះៗ ដើម្បីប្រល័យពូជសាសន៍ខ្មែរបន្ត មាន៥ចំណុចសំខាន់ៗគឺ:

រដ្ឋអំណាចទី១: គឺរដ្ឋាភិបាលវៀតណាមយួនក្រហមក្លែងភេទ ដឹកនាំដោយគណបក្សប្រជាជនកម្ពុជាបច្ចុប្បន្ន ស្ថិតនៅលើតែបុគ្គលបួនដប់នាក់ដដែលៗ ចាប់តាំងតែពីថ្ងៃ៧មករា១៩៧៩ នោះមកម្លេះ ។ ដោយការតែងតាំងពី « អង្គការលើ » វៀតណាមយួនក្រហមដែលមានបាតដៃប្រឡាក់ឈាមខ្មែរ តាំងតែពីថ្ងៃ១៧មេសា១៩៧៥នោះផងដែរ ដែលមានរដ្ឋអំណាចដូចជានិតិបញ្ញត្តិ និតិប្រតិបត្តិ និងនិតិក្រម ហៅថា: អំណាចតុលាការឧបករណ៍ជាដើមនោះ ។

រដ្ឋអំណាចទី២: គឺប្រជាជនអន្តោប្រវេសន៍វៀតណាមខុសច្បាប់ ដែលបានបង្ហូរចូលកម្ពុជាដូចទឹកបាក់ទំនប់ ដោយរួមទាំងពពួកចារកិច្ចវៀតណាមយួនក្រហមស្លៀកពាក់ស៊ីវិលបង្កប់នៅហ្វូងជនអន្តោប្រវេសន៍ខុសច្បាប់ទាំងនោះ ដែលបានបង្កើត « អង្គការ » នៃក្រុមបងតូចបងធំ ដើម្បីបង្ករភាពវឹកវរ ចលាចល ធ្វើព្យុះធ្វើភ្លៀងនៅក្នុងសង្គមខ្មែរឥតឈប់ឈរ គឺដោយសារតែមាន « អង្គការលើយួនបាក់គី » នៅកម្ពុជាដែលជាមេក្លោងនៃក្រុមបងតូចបងធំ ដែលបានជ្រើសរើសចេញពីពពួកក្មេងពាល ក្មេងអនាថា បំពុលស្មារតីដោយថ្នាំញៀននោះឯង ។ ដែលហៅថា « អង្គការយួនបាក់គី » នោះ គឺជាអង្គការមួយបង្កើតឡើងដោយជនជាតិយួននៅភូមិភាគខាងជើងនៃប្រទេសយួន គឺជាជនជាតិយួនដែលស្គាល់តែការលំបាកតោកយ៉ាកវេទនាបំផុតក្នុងជីវភាពប្រចាំថ្ងៃ ។ ជួនកាល « អង្គការយួនបាក់គី » នេះ បានបញ្ជូរឲ្យក្រុមខ្លួន ទៅសម្លាប់ក្រុមមួយទៀតដើម្បីបំបាត់ភស្តុតាងបំបិតមាត់នោះក៏មាន ។ នេះហើយគឺជា « យុទ្ធសាស្ត្រយកកំពិសទៅដូរបង្កង » ឬ « យកត្រីតូច ដូរយកត្រីធំ » នោះ ។ ដូច្នេះ យុវជនខ្មែរគ្រប់រូបដែលបានឈានជើងចូលក្នុង « អង្គការយួនបាក់គី » ណាមួយនោះត្រូវភ្ញាក់ស្មារតីឡើង រួចគេចចេញឲ្យផុតពី « អង្គការយួនបាក់គី » នេះ ។ អង្គការនេះអាចប្តូរឈ្មោះជាច្រើនថែមទៀតក៏មាន។

រដ្ឋអំណាចទី៣: គឺសមាគមវៀតណាមយួនក្រហមនៅកម្ពុជា ដែលជាប្រព័ន្ធនៃ « អង្គការចាត់តាំង » ក្រុមស្នូលដើម្បីរៀបចំមូលដ្ឋាននៃយុទ្ធសាស្ត្រផ្សេងៗ ដូចជាការបង្កើតអំពើចារកម្មជាដើម ។ ល ។

រដ្ឋអំណាចទី៤: គឺរដ្ឋាភិបាលអំណាចយួនក្រហមភ្នំពេញ បានបង្កើតច្បាប់បំពានសិទ្ធិសេរីភាពពលរដ្ឋខ្មែរដោយយកផ្លាក « អភិវឌ្ឍន៍សេដ្ឋកិច្ច » ជំនួសផ្លាក « ប្រល័យពូជសាសន៍ » វិញ ដូចជាការផ្តល់ដីសម្បទានរាប់លានហិកតា ក្នុងកិច្ចសន្យា៩៩ឆ្នាំមិនចេះចប់ ដើម្បផ្តល់ការងារសំរាប់អានិកជនយួនខុសច្បាប់ ពង្រីកពង្រឹងសេដ្ឋកិច្ចរបស់ខ្លួន ជាកត្តាចម្បងក្នុងការឈ្លានពានកម្ពុជា ។

ពាក្យស្លោកមួយឃ្លាត្រូវបានអ្នកប្រាជ្ញថែងថា: « ធ្វើស្រែនឹងទឹកធ្វើសឹកនឹងបាយ » ។ ដូចជាការវាយកំទេចសេដ្ឋកិច្ចប្រជាពលរដ្ឋខ្មែរ ឆក់ ប្លន់ដីស្រែចំការ វាយកំទេចភូមិថាន ភូមិគ្រឹះ ជាដើម ។ ល ។

រដ្ឋអំណាចទី៥: គឺគណកម្មាធិការជាតិ រៀបចំការបោះឆ្នោតដែលសុទ្ធសឹងតែក្រុមមនុស្សដែល « អង្គការលើ »

វៀតណាមយួនក្រហមបានចាត់តាំងបញ្ជូនមកតាមរយៈគណបក្សប្រជាជនកម្ពុជា ដែលបានផ្តល់អំណាចរំលោភបំពានរដ្ឋធម្មនុញ្ញខ្មែរ និងធម្មនុញ្ញអន្តរជាតិ ឲ្យពពួកជនអន្តោប្រវេសន៍យួនខុសច្បាប់ទាំងនោះ កាន់អត្តសញ្ញាណប័ណ្ណខុសច្បាប់ ទៅបោះឆ្នោតខុសច្បាប់ ដើម្បីជ្រើសរើសអ្នកដឹកនាំរដ្ឋាភិបាលក្បត់ជាតិខ្មែរ ក្រោមអំណាចវៀតណាមយួនក្រហមជំនួសពលរដ្ឋខ្មែរបរិសុទ្ធ ដែលមានបុព្វសិទ្ធិជាម្ចាស់ប្រទេសខ្លួនឯងនោះទៅវិញ ។

សរុបសេចក្តីទៅ បានន័យថា: « អង្គការលើ » វៀតណាមយួនក្រហម បានធ្វើជាមេបាចែចូវការចរចារកិច្ចព្រមព្រៀងសន្តិភាព ស្តីពីកម្ពុជាថ្ងៃ២៣តុលា១៩៩១ផង និងធ្វើជាមេឧក្រិដ្ឋជនប្រល័យពូជសាសន៍ខ្មែរដោយសម្លាប់កិច្ចព្រមព្រៀងថ្ងៃ២៣តុលា១៩៩១ផង ដូច្នេះវៀតណាមយួនក្រហមជាសត្រូវពិតសួរពូជម៉ឺនឆ្នាំ របស់ខ្មែរនិងសហាគមអន្តរជាតិនោះផងដែរ ។

ការបោះឆ្នោតសេរីអយុត្តិធម៌ពហុបក្សនៅកម្ពុជា រដ្ឋាភិបាលរដ្ឋអំណាចវៀតណាមយួនក្រហម ត្រួតត្រាខ្មែរតាមរយៈគណបក្សប្រជាជនកម្ពុជា មិនបានគោរពអនុវត្តកិច្ចព្រមព្រៀងសន្តិភាពស្តីពីកម្ពុជាសោះឡើយ ។ គឺបានគោរពអនុវត្តត្រឹមតែមួយជ្រុងតូចប៉ុណ្ណោះ ដូចជាការបោះឆ្នោតដោយសេរីអយុត្តិធម៌ រួចហើយមេបនបរិវាររបស់អង្គការលើវៀតណាមយួនក្រហមបានស្រែកជំទាលក្តែងៗថា: កិច្ចព្រមព្រៀងថ្ងៃ២៣តុលានេះ បានស្លាប់បាត់ទៅហើយ ។ បើនរណានិយាយរំលឹកខួបថ្ងៃ២៣តុលា១៩៩១ គឺសត្វធាតុ ។ បើនរណានិយាយការពិត វាយប្រហារខួបថ្ងៃ៧មករា១៩៧៩ គឺសត្វតិរិច្ឆាន ។

ដូច្នេះគ្រប់វិស័យទាំងអស់ក្នុងស្ថាប័នរដ្ឋក្តី ក្រុមហ៊ុនឯកជនក្តី ការអភិវឌ្ឍន៍កសាងប្រទេសក្តី ការពារសមិទ្ធិផលសង្គមក្តី តាមរយៈការត្រួតត្រានៃរដ្ឋអំណាចរបស់គណបក្សប្រជាជនកម្ពុជា គឺមិនមែនសំរាប់ប្រទេសកម្ពុជា និងក៏មិនមែនដើម្បីពលរដ្ឋខ្មែរបរិសុទ្ធនោះដែរ គឺគ្រាន់តែជាការធ្វើប្រជាភិថុ ដើម្បីទាញយកផលប្រយោជន៍ សំរាប់គណបក្សប្រជាជនកម្ពុជា ដែលបានកំពុងត្រួតត្រាកម្ពុជាតាមគោលមាគ៌ានយោបាយវាតទីលេបទឹកដី នៃមហិច្ឆិតារបស់មេបនប្រល័យពូជសាសន៍វៀតណាមយួនក្រហមខ្មោចហូ-ជីមិញនោះឯង ។

ចំណែកខ្មែរមួយក្រុមតូចបានកំពុងខំបញ្ចេញអំនួតអួតអាងរបស់ខ្លួនថា: គឺមិនត្រូវមានតែគណបក្សនយោបាយមួយប៉ុណ្ណោះទេដែលបានកំពុងប្រយុទ្ធប្រឆាំងជាមួយរដ្ឋាភិបាលបំរើមហិច្ឆិតាអំណាច « អង្គការលើ » វៀតណាមយួនក្រហមនៅកម្ពុជា ដែលមានសមមិត្តនាយករដ្ឋមន្ត្រីហ៊ុន-សែនជាតំណាងនោះ ។

គឺមានអាត្មាខ្លួនម្នាក់ផងដែរ ដែលមានទេពកោសលអាចបង្កើតគណបក្សនយោបាយ ដើម្បីឈរធ្វើមេបក្សអាចបង្កើតចលនាដើម្បីឈរធ្វើមេចលនាបានដូចគេឯងអញ្ចឹងដែរ ។ នេះគឺជាសិទ្ធិរបស់ខ្លួនអាត្មាម្នាក់ៗ ។

ទោះបីបើនិយាយអំពីសិទ្ធិរបស់ខ្លួនអាត្មាម្នាក់ៗក៏ពិតមែន ប៉ុន្តែក្នុងនាមជាកុលបុត្រកុលធីតាខ្មែរ ដែលជាពុទ្ធសាសនិកជន ដើរតាមគន្លងព្រះពុទ្ធសាសនាពុទ្ធឱវាទបានសំដែងថា: កាលញ្ញូតា គឺត្រូវស្គាល់កាលទេសៈ ដែលគួរបង្កើតគណបក្សនយោបាយ ឬចលនានេះ ចលនានោះ ឬមិនគួរបង្កើត ។ កាលណាបើបានបង្កើតគណបក្សនយោបាយ ឬចលនាផ្សេងៗគ្នាហើយនោះ ក៏បានចាប់ផ្តើមរិះគន់វាយប្រហារគ្នាទៅវិញទៅមកឥតឈប់ឈរ ដោយមិនយកបញ្ហាជាតិមកវិភាគរាវរកឧបាយជួយដោះស្រាយគ្នា ដែលមេបនប្រល័យពូជសាសន៍វៀតណាមយួនក្រហមនៅកម្ពុជា បានកំពុងប្រើប្រាស់ឧបាយកលគ្រប់រូបភាពដើម្បីបំផ្លាញកម្ពុជា សម្លាប់ពលរដ្ឋខ្មែរ ព្រះសង្ឃខ្មែរ នគរបាលខ្មែរ កងទ័ពខ្មែរបរិសុទ្ធ ទៅតាមយុទ្ធសាស្ត្រក្តៅ ឬត្រជាក់ ដើម្បីលេបត្របាក់កម្ពុជា នោះទៅវិញទេ ។

ប្រសិនបើគិតអំពីបញ្ហាជាតិទៅវិញនោះ ខ្មែរយើងម្នាក់ៗត្រូវតែលះបង់គំនិតអាត្មាផ្ទាល់ខ្លួននិយមចេញ ។ បើខ្មែរ

យើងមិនលះបង់គំនិត « អាត្មានិយម » អស្មិមានះ ទេនោះ បានន័យថាៈ ចេះស្រឡាញ់ជាតិខ្មែរខ្លួនឯងដែរ ប៉ុន្តែមិនទាន់បានលះបង់ដល់ក៏រិត ដោយចេះបន្ទន់តំរិយាបទ ដោយយកជាតិជាធំនោះទេ គឺយក « អាត្មាខ្លួនឯង » ធំជាជាងជាតិទៅវិញ ។

ក្នុងការឈរធ្វើមេបក្សនយោបាយក្តី ឬមេចលនាក្តីនោះ គឺគ្រាន់តែចង់បង្ហាញពីសមត្ថភាពបុគ្គលខ្លួនឯងជាអ្នកគ្រាន់បើតែរៀងៗខ្លួនប៉ុណ្ណោះ ។ ចំពោះបុគ្គលខាងលើនេះ ទោះបីបុគ្គលនោះបានក្លាយខ្លួនជាមេបក្ស ឬមេចលនាដែលមានមនះសិកាស្នេហាជាតិពិតប្រាកដនោះក៏ដោយ តែរាល់សកម្មភាពទាំងអស់នេះ គឺប្រាកដជាឈានចូលទៅក្នុងយុទ្ធសាស្រ្តឧបាយកលរបស់មេបនប្រល័យពូជសាសន៍វៀតណាមយួនក្រហម ដែលបានរៀបចំទុករួចជាស្រេចនោះដោយមិនដឹងខ្លួន ។ បានន័យថា « ជីករណ្តៅខ្លួនឯង រួចហើយអង្គការលើយួនក្រហមកាយកប់ឲ្យ » ។

ទ្រឹស្តីនៃមេបនប្រល័យពូជសាសន៍វៀតណាមយួនក្រហមខ្មោចហូ-ជីមិញបានចែងថាៈ « អញត្រូវតែសម្លាប់ខ្មែរ ឲ្យអស់ផុតពូជគ្រប់មធ្យោបាយ ទោះខ្មែរនោះនៅក្រោមបញ្ជារបស់អញក៏ដោយ ។ ឯខ្មែរដែលនៅសេសសល់ពីអញសម្លាប់ អញត្រូវតែធ្វើឲ្យខ្មែរទាំងអស់នោះ ភ័យខ្លាចឈឺចាប់ខ្លោចផ្សា ទ្រាំរស់លែងកើត ត្រូវតែភៀសខ្លួនចេញក្រៅប្រទេស ។ អញត្រូវតែប្រើពេលវេលាសម្លាប់ខ្មែរគ្រប់រូបភាព គ្រប់ឧបាយកល ។ អញត្រូវតែប្រើយុទ្ធសាស្រ្តខ្ចីដៃខ្មែរ ឈ្លោះចាប់សម្លាប់ខ្មែរគ្នាឯងបន្តជារៀងរហូត » ។

ចំពោះបញ្ហាជនជាប់ចោទនៃក្រុមខ្មែរក្រហមបរិសុទ្ធ លោកសាឡុត-ស យួនហៅប៉ុល-ពត លោកខៀវ-សំផនជាដើមនោះ សូមបងប្អូនជនរួមជាតិខ្មែរក្នុងនិងក្រៅប្រទេស សូមមេត្តាឈប់ស្តីបន្ទោសដាក់កំហុសលើខ្មែរជាតិសាសន៍ខ្លួនឯងតទៅទៀត ។ បើខ្មែរយើងមិនបញ្ឈប់ការស្តីបន្ទោសដាក់កំហុសលើខ្មែរខ្លួនឯងទេ នោះបានសេចក្តីថាៈ ខ្មែរយើងនឹងឈានទៅរករបបប្រល័យពូជសាសន៍ខ្លួនឯងបែបថ្មីណាមួយផ្សេងទៀតដោយមិនដឹងខ្លួន និងពិតជាឈានជើងចូលទៅក្នុងឧបាយកលនៃយុទ្ធសាស្រ្តមេបនប្រល័យពូជសាសន៍វៀតណាមយួនក្រហមដដែលៗជាក់ជាពុំខាន!

ទ្រឹស្តីរបស់វរសេនីយឯកឡុយ-នុត ដែលជានាយទាហ៊ានជាន់ខ្ពស់មួយរូបជំនាន់អាណានិគមបារាំង បានធ្លាប់មានប្រសាសន៍ថា " ខ្មែរយើងត្រូវស្គាល់សត្រូវពិតរបស់ខ្លួន មុនអន្តរជាតិស្គាល់សត្រូវពិតរបស់ខ្មែរ "

ពាក្យដែលថាៈ « សេរីពហុបក្ស » នោះគឺពិតជាត្រឹមត្រូវណាស់ ។ ប្រសិនបើកម្ពុជាមានឯករាជ្យជាតិ សន្តិភាព សិទ្ធិសេរីភាព អធិបតេយ្យភាព ពិតមែនដូចបណ្តាប្រទេសមួយចំនួនលើពិភពលោក ដូចជាសហរដ្ឋអាមេរិក បារាំង អង់គ្លេស កាណាដា ជាដើម.........ដែលប្រកាន់ខ្ជាប់នូវលិទ្ធិប្រជាធិបតេយ្យសេរីពហុបក្សពិតប្រាកដ ។ បើប្រទេសជិតខាងកម្ពុជាវិញ ដូចជាប្រទេសថៃជាដើមនោះ ។

ចំណែកកម្ពុជាយើងវិញនោះ គឺគ្មានទេឯករាជ្យជាតិ សន្តិភាព អធិបតេយ្យភាព គឺមានតែសេរីពហុបក្ស សេរីពហុចលនា ពហុខេត្រ ពហុសមាគមយួនពេញប្រទេសកម្ពុជា ពហុសង្ឃប៉ូលិសតិញសង្ឃយួន ពហុអន្តោប្រវេសន៍យួនខុសច្បាប់ កាន់អត្តសញ្ញាណប័ណ្ណខុសច្បាប់ ទៅបោះឆ្នោតដោយសេរីខុសច្បាប់ជាតិខ្មែរ និងអន្តរជាតិទៀតផង ។ ចុះចំណែកនៅកម្ពុជាក្រោមវិញ តើមានសេរីពហុបក្ស ពហុសមាគម ពហុចលនា ដែរឬទេ?

ដូច្នេះការបង្កើតគណបក្សនយោបាយច្រើន ចលនាច្រើន រួចធ្វើសកម្មភាពវាយប្រហារខ្មែរគ្នាឯង ដោយធ្វើការរិភាគតែចំពោះខ្មែរស្នេហាជាតិដូចគ្នានោះ សួរថាៈ តើអាចឈានទៅរកភាពសាមគ្គីធ្លុងមួយ មហាជោគជ័យបានដែរឬទេ? ក្នុងយុទ្ធសាស្រ្តរំដោះសង្គ្រោះជាតិខ្មែរនោះ? តែបើឆ្ពោះទៅរកសេចក្តីអន្តរាយនោះ គឺប្រាកដជាជាង ។ ប៉ុន្តែបើក្រោយការរំដោះសង្គ្រោះកម្ពុជាឱយឲ្យផុតពីចង្កូមក្រពើយួនក្រហមហើយនោះ ទោះបីខ្មែរយើងបង្កើតគណបក្សនយោបាយ ឬចលនា

ផ្សេងៗប៉ុន្មានបន្ថែមទៀត ក៏មិនទាស់ខុសអ្វីដែរ ។

ខ្មែរយើងត្រូវតែបង្កើត « អង្គការមហាជនខ្មែរឯករាជ្យ » មួយនៅគ្រប់បណ្តាប្រទេសទាំងអស់ជុំវិញពិភពលោក ដើម្បីដាក់ពាក្យប្តឹង ជម្រុញស្នើរសុំឲ្យសហគមអន្តរជាតិ ត្រូវតែប្រើឥទ្ធិពលអំណាចនៃច្បាប់របស់ខ្លួន ស្តីពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ប្រទេសបារាំងស្តីពីកម្ពុជានាថ្ងៃទី២៣ខែតុលាឆ្នាំ១៩៩១ និងត្រូវពិនិត្យឲ្យបានច្បាស់លាស់ ស្តីពីស្ថានការណ៍នយោបាយ សង្គ្រាមសេដ្ឋកិច្ច ប្រល័យពូជសាសន៍នៃរដ្ឋអំណាចវៀតណាមយួនក្រហមនៅកម្ពុជា តាមរយៈរដ្ឋាភិបាលនៃគណបក្សប្រជាជនកម្ពុជា ។

« អង្គការមហាជនខ្មែរឯករាជ្យ » ត្រូវតែដាក់ពាក្យប្តឹង ជម្រុញស្នើរសុំឲ្យសហគមអន្តរជាតិ ត្រូវតែប្រើឥទ្ធិពលអំណាចនៃច្បាប់របស់ខ្លួន ដើម្បីរើរុះទីតាំងកូនកាត់អន្តរជាតិនៅទីក្រុងភ្នំពេញទៅតាំងមូលដ្ឋាននៅទីក្រុងឡាអេ ប្រទេសហូឡង់វិញ ទើបអាចស្វែងរកយុត្តិធម៌បរិសុទ្ធជូនវិញ្ញាណខ័ន្ធខ្មែរដែលបានស្លាប់អស់ជាង៣លាននាក់ ក្នុងរបបប្រល័យពូជសាសន៍វៀតណាមយួនហាណូយនាថ្ងៃ១៧មេសា១៩៧៥ ដោយប្រើ « យុទ្ធសាស្ត្រច្រេះស៊ីដែក » ក្នុងការខ្ចីដៃខ្មែរសម្លាប់ខ្មែរបន្ត ។ ឧទាហរណ៍ជាក់ស្តែង ដូចរបបប្រល័យពូជសាសន៍បែបថ្មីវៀតណាមយួនហាណូយនៅកម្ពុជា តាមរយៈគណបក្សប្រជាជនកម្ពុជា ដែលបានកំពុងប្រល័យពូជសាសន៍ខ្មែរគ្រប់រូបភាព ដោយសង្គ្រាមសេដ្ឋកិច្ចនោះ ។

យើងជាប្រជាពលរដ្ឋខ្មែរ សូមអំពាវនាវស្នើរសុំឲ្យសហគមអន្តរជាតិ មិនត្រូវយកជីវិតប្រជាពលរដ្ឋខ្មែរ ទៅលេងសើចជាមួយរដ្ឋអំណាចយួនហាណូយនៅកម្ពុជា តាមរយៈរដ្ឋអំណាចនៃគណបក្សប្រជាជនកម្ពុជានោះឡើយ ដើម្បីឲ្យសមស្របទៅតាមនិយមន័យពាក្យថា: « ប្រទេសមានម្ចាស់ ពិភពលោកមានច្បាប់ » នោះ ។

ដូច្នេះក្រុមឧក្រិដ្ឋជន ដែលបានសម្លាប់ខ្មែរអស់ជាង៣លាននាក់ ក្នុងរបបប្រល័យពូជសាសន៍នាថ្ងៃ១៧មេសា១៩៧៥ នោះ គឺមិនមែនក្រុមលោកសាឡុត-ស យួនហៅប៉ុល-ពត លោកខៀវ-សំផន ជាអ្នកផ្តើមគំនិតសម្លាប់ខ្មែរជាតិសាសន៍ខ្លួនឯងនោះទេ ប៉ុន្តែគឺជាក្រុមអ្នកនយោបាយស្ទើរភ្លើង ត្រូវចាញ់ឧបាយកលយុទ្ធសាស្ត្រនយោបាយរបស់ « អង្គការលើ » វៀតណាមយួនក្រហមហាណូយ បានកំពុងសម្លាប់ខ្មែរបន្ត តាមរយៈគណបក្សប្រជាជនកម្ពុជានេះឯង ។

វប្បធម៌ប្រពៃណីខ្មែរស្នេហាជាតិបរិសុទ្ធតាំងពីបុរាណកាលមក គឺមានកាតព្វកិច្ចការពារខ្មែរ ជាតិសាសន៍ដូចគ្នាទៅវិញទៅមក ដោយការព្រួតដៃគ្នាសាមគ្គីធម៌ធ្លងមួយ ។ ពាក្យស្លោកមួយឃ្លាត្រូវបាន អ្នកប្រាជ្ញចែងថា: « ស៊ូស្លាប់ដើម្បីរស់ » « ស៊ូស្លាប់លើទឹកដីកំណើតរបស់ខ្លួន » « ការពារកេរ្តិ៍តំណែល ទុកសំរាប់កូនចៅខ្មែរជំនាន់ក្រោយ » ។

ចំពោះខ្មែរស្នេហាជាតិបរិសុទ្ធ គឺមិនត្រូវស្លាប់ដោយខ្វះការពិចារណា ស្លាប់ឥតន័យ ដោយប្រការលោតទឹក ចងកលេបថ្នាំ អារ ក ឬដោយប្រការឥតន័យណាមួយនោះឡើយ គឺត្រូវតែ « ស៊ូស្លាប់ដើម្បីការពារកេរ្តិ៍តំណែល ទុកសំរាប់កូនចៅខ្មែរជំនាន់ក្រោយ » ។ នេះគឺជាច្បាប់ធម្មជាតិលោកបានបង្កើត និងជាវប្បធម៌ប្រពៃណីខ្មែរ តាំងតែពីបុរាណកាលគ្រប់តំណរៀងមក បានចែងថា: « ទីណាមានការជិះជាន់ ទីនោះត្រូវតែមានការរើបំរះជានិច្ច » ។

ទីអវសាននៃថ្ងៃអស់ល័ក្ខរបស់មេបនប្រល័យពូជសាសន៍វៀតណាមយួនក្រហមហាណូយ បានកំពុងខិតចូលជិតមកដល់ទីបរាជ័យហើយ ដោយសារតែថ្ងៃប្រវត្តិសាស្ត្រដ៏មានសារៈសំខាន់សំរាប់ប្រជាជាតិខ្មែរ ត្រូវតែបានទទួលភាពយុត្តិធម៌បរិសុទ្ធ ពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិទីក្រុងឡាអេ ប្រទេសហូឡង់ ដើម្បីវែកមុខមេបនវាតទីនិយមវៀតណាមយួនក្រហមប្រល័យពូជសាសន៍ខ្មែរថ្ងៃ១៧មេសា១៩៧៥ និងថ្ងៃ៧មករា១៩៧៩ ជាក់ជាពុំខាន!

ថ្ងៃប្រវត្តិសាស្ត្រដ៏មានសារៈសំខាន់ សំរាប់ប្រជាជាតិខ្មែរនោះ គឺថ្ងៃ២៣តុលា១៩៩១ នៃកិច្ចព្រមព្រៀងសន្តិភាពទី

ក្រុងប៉ារីស ប្រទេសបារាំង ស្តីពីកម្ពុជាដែលមានសហគមអន្តរជាតិបានដឹងឮពាសពេញពិភពលោករួចអស់ទៅហើយ ដោយរង់ចាំតែការចូលរួមចំណែកនៃអំណាចមហាជនខ្មែរបរិសុទ្ធគ្រប់ទិសទីក្រោកឈរទាមទារសិទ្ធិសេរីភាពរបស់ខ្លួន ដោយយោលទៅតាមមាត្រានៃច្បាប់សិទ្ធិប្រជាពលរដ្ឋលើពិភពលោកបានចែងក្នុងមាត្រា៣ថា: បុគ្គលម្នាក់ៗ ត្រូវមានសិទ្ធិរស់រានមានជីវិត មានសិទ្ធិសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។ **មាត្រា៩បានចែងថា:** គ្មានបុគ្គលណាម្នាក់បានត្រូវទទួលរងការចាប់ខ្លួន វាយដំ ឃុំឃាំងខ្លួន ឬនិរទេសខ្លួន តាមអំពើចិត្តនោះបានឡើយ ។ មាត្រា១៧បានចែងថា: មនុស្សគ្រប់រូប មានសិទ្ធិជាម្ចាស់កម្មសិទ្ធដូចជាដីស្រែចំការ ផ្ទះសម្បែងជាដើម ជាកម្មសិទ្ធផ្ទាល់ខ្លួន ឬជាសមូហភាព និងគ្មានជនណាម្នាក់ ត្រូវគេដកហូតកម្មសិទ្ធរបស់ពលរដ្ឋ តាមតែអំពើចិត្តអំណាចបំពាននោះបានឡើយ ។

សិទ្ធិអំណាចពលរដ្ឋលើពិភពលោកនេះ ត្រូវបានទទួលស្គាល់ គោរព អនុវត្តន៍ ដោយអង្គការអន្តរជាតិចុះថ្ងៃទី១០ខែធ្នូឆ្នាំ១៩៤៨ នោះមកម្លេះ ។

ដូច្នេះកងទ័ពខ្មែរ នគរបាលខ្មែរ ព្រះសង្ឃខ្មែរ ពលរដ្ឋខ្មែរបរិសុទ្ធទាំងអស់ ត្រូវតែហ៊ានក្រោកឈរឡើង ទាមទារសិទ្ធិសេរីភាព ឯករាជ្យជាតិខ្មែរ តាមរយះអំណាចនៃច្បាប់អន្តរជាតិ គឺកិច្ចព្រមព្រៀងសន្តិភាព ស្តីពីកម្ពុជាថ្ងៃទី២៣ខែតុលាឆ្នាំ១៩៩១ ។ នេះគឺជាបុព្វហេតុដ៏ត្រឹមត្រូវសំរាប់ប្រជាជាតិខ្មែរ និងមិនមានអនុភាពណាអាចលុបបំបាត់ចោល នូវកិច្ចព្រមព្រៀងសន្តិភាព ស្តីពីកម្ពុជាថ្ងៃ២៣តុលា១៩៩១នេះបានជាដាច់ខាត និងមិនមានអនុភាពណាអាចទប់ស្កាត់ចរន្តនៃសិទ្ធិសេរីភាពនៃអំណាចពលរដ្ឋ ខ្មែរម្ចាស់ស្រុក ដើម្បីជ្រើសរើសអ្នកដឹកនាំវាសនាជាតិខ្មែរបរិសុទ្ធ ដែលប្រកបដោយគតិយុត្តិធម៌ សច្ចះធម៌ សីលធម៌ និងត្រូវតែគោរពសិទ្ធិមនុស្សជាកត្តាសំខាន់នៅកម្ពុជា!

បច្ចុប្បន្នកាលនេះ ឧបាយកលពិសពុលរបស់អង្គការលើវៀតណាមយួនហាណូយ មិនអាចបំភ័ន្តមតិជាតិខ្មែរបរិសុទ្ធ និងអន្តរជាតិបានទេ ។ គឺមិនមែនជំនាន់ទុំនិងទាវដើរទូលតោកលក់នោះឡើយ ។

ប្រជាពលរដ្ឋខ្មែរ ព្រះសង្ឃខ្មែរ កងទ័ពខ្មែរ នរគបាលខ្មែរ បរិសុទ្ធទាំងអស់ ក្នុងនាមកុលបុត្រ កុលធីតាខ្មែរ ដែលមានបេះដូងតែមួយ ឈាមជ័រតែមួយ ដែលមានជីវិត៣: លើទឹកដីខ្មែរកម្ពុជាក្រោម ខ្មែរកម្ពុជាកណ្តាល ខ្មែរកម្ពុជាសុរិន ត្រូវក្រោកឈរឡើង ច្រៀងទង់ស្នេហាជាតិបរិសុទ្ធ ដើម្បីសំរេចគោលដៅតែមួយ ពេលវេលាតែមួយ ដោយយោលទៅតាមច្បាប់ស្តីពីសិទ្ធិមនុស្សគ្រប់ពូជសាសន៍ ដែលរស់នៅលើទឹកដីកំណើតរបស់ខ្លួន ដែលបានទទួលស្គាល់ គោរព អនុវត្តន៍ និងបានប្រកាសជាសាកល ដោយអង្គការសហប្រជាជាតិ ចាប់តាំងពីឆ្នាំ១៩៤៨នោះ ។

ទ្រឹស្តីនៃអ្នកប្រាជ្ញបានចែងថា: « បាងកករលំ ហាណូយរលាយ ហូ-ជីមិញបែកខ្ចាយ សប្បាយនរគខ្មែរ » ។

ដូច្នេះសត្រូវពិតរបស់ខ្មែរគឺ: « មេបនប្រល័យពូជសាសន៍វៀតណាមយួនក្រហមថ្ងៃ១៧មេសា១៩៧៥ » ដែលមាន « អង្គការលើ អង្គការបក្ស និងអង្គការចាត់តាំង » នោះឯង និងរួមទាំង « មេបនប្រល័យពូជសាសន៍វៀតណាមយួនក្រហមហាណូយវាតទីនិយម បំបាត់ពូជសាសន៍ខ្មែរបន្ត » នៅក្នុងទ្រង់ទ្រាយបំភ័ន្តមតិជាតិខ្មែរនិងអន្តរជាតិ « ថ្ងៃ៧មករា១៩៧៩ » ដោយខ្ញីដៃគណបក្សប្រជាជនកម្ពុជាដែលបានកំពុងកាន់អំណាច នៃប្រមុខរដ្ឋាភិបាលនៅក្នុងប្រទេសខ្មែរយើងនេះ ។

ដូច្នេះសង្គ្រាមប្រល័យពូជសាសន៍បែបថ្មីវៀតណាមយួនហាណូយនៅកម្ពុជា គឺជាសង្គ្រាមរវាងខ្មែរនិងវៀតណាមយួនហាណូយ នឹងពិតជាសង្គ្រាមថៃវាយប្រហាររដ្ឋអំណាចយួនហាណូយយ៉ាងពិតប្រាកដ និងក៏មិនមែនសង្គ្រាមរវាងខ្មែរនិងខ្មែរ និងក៏មិនមែនសង្គ្រាមថៃនិងខ្មែរនោះដែរ ។

មេបនឧក្រិដ្ឋជនប្រល័យពូជសាសន៍វៀតណាមយួនក្រហម ពិតជាត្រូវបានបើករបាំងមុខដោយសារស្នាដៃកូនខ្មែរ

និងអំណាចនៃច្បាប់របស់សហគមអន្តរជាតិ ក្នុងពេលឆាប់ៗខាងមុខនេះជាក់ជាមិនខាន!

ដូច្នេះមហិច្ឆិតានៃមេបនប្រល័យពូជសាសន៍ វៀតណាមយួនក្របាមហាណូយ ត្រូវតែអស់ល័ក្ខនៅកម្ពុជា!

ធ្វើនៅប្រទេសបារាំង ថ្ងៃទី១ខែមករា ឆ្នាំ២០១២

អតីតកម្មាភិបាល នៃកងយោធាពិសេស នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា

**ហែម-វណ្ណធន**